# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ក្រុងគ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

## សេចក្ដីថ្លែងការណ៍
## រដ្ឋាភិបាលកម្ពុជា ដោះលែងសកម្មជនសេរីភាពទាំងអស់ជាបន្ទាន់

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមថ្កោលទោសយ៉ាងដាច់អហង្កា ចំពោះអាជ្ញាធររដ្ឋាភិបាលកម្ពុជា ដែលចាប់ឃាត់ខ្លួន សមាជិកក្រុមយុវជនខ្មែរថាវរៈជាបន្តបន្ទាប់ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ រួមមានយុវតី **ឈឿន ដារ៉ាវី**, លោក **ហ៊ុន វណ្ណៈ**, លោក **យ៉ង សៀងហៃ**, យុវតី **ថា ឡាវី**, យុវតី **ជា គន្ធីន** និងលោក **ស្វាយ សំណាង** ហើយនៅថ្ងៃទី១៤ ខែសីហា លោក **សួង សុភ័ណ្ឌ** ប្រធានគណបក្សខ្មែរឈ្នះ ក៏ត្រូវបានចាប់ឃាត់ខ្លួនផងដែរ ខណៈពេលពួកគាត់ធ្វើយុទ្ធនាការរួមគ្នា នៅទីក្រុងភ្នំពេញ ដើម្បីទាមទារយុត្តិធម៌ជូនលោក **រ៉ុង ឈុន** ប្រធានសហភាពសហជីពកម្ពុជា និងជាតំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ក្នុងរយៈពេល ២សប្ដាហ៍មកនេះ។ ករណីការចាប់ឃាត់ខ្លួនក្រុមសកម្មជនទាំងនេះ ជាការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើរដ្ឋធម្មនុញ្ញកម្ពុជា ត្រង់កថាខណ្ឌទី១ នៃមាត្រា៣៥ និងកថាខណ្ឌទី១ នៃមាត្រា៤១ ព្រមទាំងរំលោភលើមាត្រា១៩ នៃសេចក្ដីប្រកាសជាសកល ស្ដីពីសិទ្ធិមនុស្ស។

រដ្ឋាភិបាលកម្ពុជារបស់លោក **ហ៊ុន សែន** កំពុងរុញច្រានស្ថានការប្រទេសកម្ពុជា ឲ្យបន្តធ្លាក់ក្នុងវិបត្តិធ្ងន់ធ្ងរនៃការ អនុវត្តអំណាចផ្ដាច់ការ ដែលប្រាសចាកពីខ្លឹមសាររដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១។ ទង្វើរបស់រដ្ឋាភិបាលលោក **ហ៊ុន សែន** គឺជាការរំលោភសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងបំបិទសិទ្ធិបញ្ចេញមតិរបស់ពលរដ្ឋ ដែលអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការទាមទារយុត្តិធម៌សង្គម ការគោរពសិទ្ធិមនុស្ស សិទ្ធិដីធ្លី និងទាមទារឲ្យមានតម្លាភាពក្នុងការដោះស្រាយបញ្ហាព្រំដែន ជាមួយប្រទេសវៀតណាម។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមអំពាវដល់រដ្ឋាភិបាល និងតុលាការកម្ពុជា ត្រូវដោះលែង**ក្រុមសកម្មជនទាំងអស់** ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ ដើម្បីរួមចំណែកលើកកម្ពស់សិទ្ធិមនុស្ស សិទ្ធិបញ្ចេញមតិ សិទ្ធិជួបប្រជុំជាសាធារណៈរបស់ពលរដ្ឋឡើងវិញ ហើយរួបរួមគ្នាការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដីខ្មែរ ស្របតាមខ្លឹមសាររដ្ឋធម្មនុញ្ញកម្ពុជា គោលការណ៍ច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១។

**ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ម៉ែន ណាត**

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact nathamonin@gmail.com /
Hompage: https://cwcicambodia.net